**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ : ០០៤៩/១១ ក.អ.ជ

រាជធានីភ្នំពេញ ថ្ងៃទី.១៦.ខែ.កុម្ភៈ.ឆ្នាំ២០១១..

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
អគ្គលេខាធិការដ្ឋាន
ចូល លេខ......
ថ្ងៃទី១៧-០២-១១ម៉ោង១៥:០០
បញ្ជូន......

# ប្រកាស

# ស្តីពី

# ការបង្កើតក្រុមការងារដើម្បីកុមារ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/ ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២០៩/១២០១ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្ម លើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញសេចក្តីសម្រេចលេខ ១២៧ ក.ជ.ក ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ២០១០ ស្តីពីការបង្កើតក្រុមការងារដើម្បីកុមារនៅតាមក្រសួង-ស្ថាប័ន
- យោងតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមការងារដើម្បីកុមាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានសមាសភាពដូចខាង



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 539
ទូរសារ (855) 23 991 117 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

ក្រោម៖

| | | |
|---|---|---|
| ១. លោកជំទាវ **ម៉ាត់ ម៉ារ៉ា** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. លោក **ឌួច សំណាង** | អគ្គនាយករងបច្ចេកទេស | អនុប្រធាន |
| ៣. លោកវេជ្ជ. **ចេង ដូរ៉ាន** | អនុប្រធាននា.ថែទាំសុខភាពជនបទ | សមាជិក |
| ៤. លោកស្រី **ឡាច សាម៉ន** | អនុប្រធាននា.រដ្ឋបាល និងបុគ្គលិក | សមាជិក |
| ៥. លោកស្រី **ចាន់ ច្រិប** | អនុប្រធាននា.សវនកម្មផ្ទៃក្នុង | សមាជិក |
| ៦. កញ្ញា **កាយ សុធាទី** | អនុប្រធាននា.ផ្លូវលំជនបទ | សមាជិក |
| ៧. លោក **ឆិន ហ្មេសោល** | អនុប្រធាននា.អភិវឌ្ឍន៍សហគមន៍ | សមាជិក |
| ៨. លោក **សេង អ៊ាមហ៊ីរ** | អនុប្រធាននា.ផ្គត់ផ្គង់ទឹកជនបទ | សមាជិក |
| ៩. លោក **ហ៊ុយ ជីវិត** | អនុប្រធាននា.ផែនការនិងទំនាក់ទំនងសាធារណៈ | សមាជិក |
| ១០.លោកស្រី **ឈាង សុខណា** | អនុប្រធាននា.អភិវឌ្ឍន៍ជនជាតិភាគតិច | សមាជិក |
| ១១.លោក **ស៊ុំ ស៊ីថា** | មន្ត្រីនាយកដ្ឋានថែទាំសុខភាពជនបទ | សមាជិក |

**ប្រការ ២ .-**

ក្រុមការងារដើម្បីកុមារក្រសួងអភិវឌ្ឍន៍ជនបទ គឺជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនក្រុមការងារជាតិកម្ពុជាដើម្បីកុមារ "**ក.ជ.ក**" លើការងារទំនាក់ទំនង និងការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារការលើកកម្ពស់សុខុមាលភាពនិងការចូលរួមចំណែករបស់កុមារក្នុងក្រសួងអភិវឌ្ឍន៍ជនបទ ។

**ប្រការ ៣ .-**

ក្រុមការងារកុមាររបស់ក្រសួងអភិវឌ្ឍន៍ជនបទមានតួនាទី ដូចតទៅ៖

- ពិគ្រោះយោបល់សម្របសម្រួលសកម្មភាពទាំងឡាយដែលពាក់ព័ន្ធទៅនឹងបញ្ហាកុមារ នៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ
- ពិនិត្យ តាមដាន វាយតម្លៃ លើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ កម្មវិធីជាតិសម្រាប់កុមារ នៅក្រសួងស្ថាប័ន និងលើកសំណើជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ "**ក.ជ.ក**" និងបញ្ហាទាំងឡាយដែលធានាឧត្តមប្រយោជន៍របស់កុមារនៅក្នុងក្រសួង
- ធ្វើការផ្សព្វផ្សាយច្បាប់ អនុសញ្ញាស្តីពីសិទ្ធិកុមារ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ "**ក.ជ.ក**" ពាក់ព័ន្ធនឹងបញ្ហានានារបស់កុមារ និងបំផុសចលនាគាំទ្រការអនុវត្តសិទ្ធិកុមារឲ្យមានប្រសិទ្ធិភាព